# ព្រះរាជក្រម

## យើង

នស/រកម/១០០៤/០០៦

## ព្រះបាទសម្ដេចព្រះ នរោត្ដម សីហនុ
## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
## និករោត្ដម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
## ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស /រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតទីស្ដីការគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៨០១/១២ ចុះថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ ២០០១ ច្បាប់ស្ដីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ

-បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ ស្ដីពីវិសោធនកម្មមាត្រា ២ មាត្រា ៣ មាត្រា ៩ មាត្រា ១០ មាត្រា ១១ មាត្រា ១៤ មាត្រា ១៧ មាត្រា ១៨ មាត្រា ២០ មាត្រា ២១ មាត្រា ២២ មាត្រា ២៣ មាត្រា ២៤ មាត្រា ២៧ មាត្រា ២៩ មាត្រា ៣១ មាត្រា ៣៣ មាត្រា ៣៤ មាត្រា ៣៥ មាត្រា ៣៦ មាត្រា ៣៧ មាត្រា ៣៩ មាត្រា ៤០ មាត្រា ៤២ មាត្រា ៤៣ មាត្រា ៤៤ មាត្រា ៤៥ មាត្រា ៤៦ និងមាត្រា ៤៧ នៃច្បាប់ស្ដីពី ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គលើកទី ១ នីតិកាលទី ៣ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ១ព្រមទាំងដែលត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញតាមសេចក្ដីសំរេចលេខ ០៦៥/០០៧/២០០៤ កបធ.ច ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៤ ហើយដែលមានសេចក្ដីទាំងស្រុងដូចតទៅ:

# ច្បាប់

## ស្តីពី

## វិសោធនកម្មមាត្រា ២ មាត្រា ៣ មាត្រា ៩ មាត្រា ១០ មាត្រា ១១ មាត្រា ១៤ មាត្រា ១៧ មាត្រា ១៨ មាត្រា ២០ មាត្រា ២១ មាត្រា ២២ មាត្រា ២៣ មាត្រា ២៤ មាត្រា ២៧ មាត្រា ២៩ មាត្រា ៣១ មាត្រា ៣៣ មាត្រា ៣៤ មាត្រា ៣៥ មាត្រា ៣៦ មាត្រា ៣៧ មាត្រា ៣៩ មាត្រា ៤០ មាត្រា ៤២ មាត្រា ៤៣ មាត្រា ៤៤ មាត្រា ៤៥ មាត្រា ៤៦ និងមាត្រា ៤៧ នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

មាត្រាមួយ.-

មាត្រា ២ មាត្រា ៣ មាត្រា ៩ មាត្រា ១០ មាត្រា ១១ មាត្រា ១៤ មាត្រា ១៧ មាត្រា ១៨ មាត្រា ២០ មាត្រា ២១ មាត្រា ២២ មាត្រា ២៣ មាត្រា ២៤ មាត្រា ២៧ មាត្រា ២៩ មាត្រា ៣១ មាត្រា ៣៣ មាត្រា ៣៤ មាត្រា ៣៥ មាត្រា ៣៦ មាត្រា ៣៧ មាត្រា ៣៩ មាត្រា ៤០ មាត្រា ៤២ មាត្រា ៤៣ មាត្រា ៤៤ មាត្រា ៤៥ មាត្រា ៤៦ និង មាត្រា ៤៧ នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/០៨០១/១២ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០១ ត្រូវបានធ្វើវិសោធនកម្មដូចតទៅ :

**មាត្រា ២ ថ្មី.-**

ត្រូវបានបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងរចនាសម្ព័ន្ធតុលាការដែលមានស្រាប់ ពោលគឺសាលាដំបូង និង តុលាការកំពូល ដើម្បីជំនុំជម្រះមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និង ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និង ការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់កម្ពុជា ដែលពាក់ព័ន្ធនឹងអំពើឧក្រិដ្ឋ ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និង ទម្លាប់អន្តរជាតិ និង ការរំលោភទៅលើអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអម្លុងថ្ងៃ ១៧ មេសា ១៩៧៥ ដល់ថ្ងៃ ៦ មករា ១៩៧៩ ។

មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និង អ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះអំពើឧក្រិដ្ឋខាងលើនេះ ហៅថា "ជនសង្ស័យ" ។

**មាត្រា ៣ ថ្មី.-**

អង្គជំនុំជម្រះវិសាមញ្ញមានអំណាចវិនិច្ឆ័យទោសជនសង្ស័យដែលបានប្រព្រឹត្តបទឧក្រិដ្ឋដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ហើយដែលបានប្រព្រឹត្តក្នុងអម្លុងថ្ងៃ ១៧ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃ ៦ មករា ឆ្នាំ ១៩៧៩ :

- មនុស្សឃាត មាត្រា ៥០១, ៥០៣, ៥០៤, ៥០៥, ៥០៦, ៥០៧ និង មាត្រា ៥០៨
- ទារុណកម្ម មាត្រា ៥០០
- ការវាយប្រហារលើសាសនា មាត្រា ២០៩ និង មាត្រា ២១០ ។

អាជ្ញាយុកាលនៃបណ្តឹងអាជ្ញានៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ដែលទាក់ទងដល់បទល្មើសខាងលើ ត្រូវបានពន្យារពេលបន្ថែម ៣០ ឆ្នាំទៀត ទៅលើអាជ្ញាយុកាលនៃបណ្តឹងអាជ្ញាសម្រាប់ឧក្រិដ្ឋកម្មទាំងឡាយខាងលើ ដែលស្ថិតក្នុងសមត្ថកិច្ចនៃអង្គជំនុំជម្រះវិសាមញ្ញ ។

ទោសប្បញ្ញត្តិចែងក្នុងមាត្រា ២០៩, ៥០០, ៥០៦ និង មាត្រា ៥០៧ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ត្រូវកំណត់ជាអតិបរមាត្រឹមទោសដាក់ពន្ធនាគារអស់មួយជីវិត អនុលោមតាមមាត្រា ៣២ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និង បញ្ជាក់បន្ថែមដោយមាត្រា ៣៨ និង មាត្រា ៣៩ ថ្មី នៃច្បាប់នេះ ។

**មាត្រា ៩ ថ្មី.–**

សាលាដំបូង ជាអង្គជំនុំជម្រះវិសាមញ្ញដោយចៅក្រមវិជ្ជាជីវៈប្រាំរូបដែលរួមមាន ចៅក្រមខ្មែរបីរូប មួយរូបធ្វើជាប្រធាន និងមានចៅក្រមបរទេសពីររូប និងមានក្រឡាបញ្ជីមួយរូប ឬ ច្រើនរូប តាមការចាត់តាំងរបស់ប្រធានចូលរួម ព្រមទាំងមានសហព្រះរាជអាជ្ញាដែលត្រូវដាក់ពាក្យប្តឹងនៅចំពោះមុខសាលាដំបូងនេះ ។

តុលាការកំពូលដែលជាកន្លែងទទួលពាក្យបណ្តឹងឧទ្ធរណ៍ផង និងសម្រេចសេចក្តីចុងក្រោយផង ជាអង្គជំនុំជម្រះវិសាមញ្ញដោយចៅក្រមប្រាំពីររូប ដែលរួមមាន ចៅក្រមខ្មែរបួនរូប ដែលមួយរូបធ្វើជាប្រធាន និង ចៅក្រមបរទេសបីរូប និង មានក្រឡាបញ្ជីមួយរូប ឬ ច្រើនរូប តាមការចាត់តាំងរបស់ប្រធានចូលរួម ព្រមទាំងមានសហព្រះរាជអាជ្ញាដែលត្រូវដាក់ពាក្យប្តឹងនៅចំពោះមុខតុលាការកំពូលនេះ ។

**មាត្រា ១០ ថ្មី.–**

ចៅក្រមជម្រះក្តីនៃអង្គជំនុំជម្រះវិសាមញ្ញ ត្រូវបានជ្រើសតាំងក្នុងចំណោមចៅក្រមក្នុងតំណែងបច្ចុប្បន្ន និង ចៅក្រមដែលបានជ្រើសតាំងបន្ថែមតាមនីតិវិធី នៃការជ្រើសតាំងចៅក្រមជាធរមាន ហើយដែលមានចរិតលក្ខណៈ និង ស្មារតីខ្ពស់មិនលំអៀង និង សុចរិតមានបទពិសោធន៍ក្នុងការងារជំនាញ ជាពិសេសខាងច្បាប់ព្រហ្មទណ្ឌ ឬ ច្បាប់អន្តរជាតិក្នុងនោះរួមមាន ច្បាប់មនុស្សធម៌អន្តរជាតិ និង ច្បាប់សិទ្ធិមនុស្សផង ។

ចៅក្រមជម្រះក្តីត្រូវឯករាជ្យក្នុងការបំពេញការងាររបស់ខ្លួន ហើយមិនត្រូវទទួល ឬ ស្វែងរកការបង្គាប់បញ្ជាពីរដ្ឋាភិបាលណាមួយ ឬ ពីប្រភពណាមួយផ្សេងទៀតឡើយ ។

**មាត្រា ១១ ថ្មី.–**

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវជ្រើសតាំងចៅក្រមខ្មែរយ៉ាងតិចប្រាំពីររូបឱ្យធ្វើជាចៅក្រមជម្រះក្តីសម្រាប់អង្គជំនុំជម្រះវិសាមញ្ញ និងជ្រើសតាំងចៅក្រមជម្រះក្តីបម្រុងមួយចំនួនតាមតម្រូវការ ព្រមទាំងត្រូវជ្រើសតាំងផងដែរនូវប្រធាននៃអង្គជំនុំជម្រះវិសាមញ្ញក្នុងចំណោមចៅក្រមខ្មែរខាងលើ តាមនីតិវិធីនៃការជ្រើសតាំងចៅក្រមជាធរមាន ។

ចៅក្រមបម្រុងខ្មែរត្រូវជំនួសចៅក្រមជម្រះក្ដីខ្មែរពេញសិទ្ធិ នៅពេលដែលចៅក្រមនេះអវត្តមាន ឬ មានធុរៈ ។ ចៅក្រមជម្រះក្ដីទាំងនេះ អាចបន្តបំពេញការងារប្រចាំថ្ងៃនៅក្នុងសាលាជម្រះក្ដីដែលខ្លួនកំពុងបំពេញ ។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវជ្រើសតាំងយ៉ាងតិច បុគ្គលប្រាំរូបដែលមានសញ្ជាតិបរទេសឱ្យធ្វើជាចៅក្រមជម្រះក្ដីបរទេសសម្រាប់អង្គជំនុំជម្រះវិសាមញ្ញ ក្រោយពីការជ្រើសរើសឱ្យឈរឈ្មោះដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

អគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវរៀបចំបញ្ជីបេក្ខជនជាចៅក្រមបរទេសដែលមានចំនួនយ៉ាងតិចប្រាំពីររូប ជូនរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ហើយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវជ្រើសតាំងចៅក្រមពេញសិទ្ធិប្រាំរូប និង ចៅក្រមបម្រុងយ៉ាងតិចពីររូបពីក្នុងបញ្ជីឈ្មោះនោះ ។ បន្ថែមពីលើចៅក្រមបរទេសដែលចូលរួមក្នុងអង្គជំនុំជម្រះវិសាមញ្ញនិងដែលមានវត្តមាននៅគ្រប់ដំណាក់កាលនៃដំណើរការជំនុំជម្រះ ប្រធានអង្គជំនុំជម្រះវិសាមញ្ញអាចចាត់តាំងតាមករណីនីមួយៗ នូវចៅក្រមបម្រុងបរទេសមួយរូប ឬ ច្រើនរូប ដែលត្រូវបានជ្រើសរើសរួចហើយ ដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅ-ក្រមឱ្យមានវត្តមាននៅដំណាក់កាលជំនុំជម្រះនីមួយៗ ហើយឱ្យជំនួសចៅក្រមបរទេសប្រសិនបើចៅក្រមរូបនោះ ពុំមានលទ្ធភាពអាចបន្តការជំនុំជម្រះតទៅទៀតបាន ។

**មាត្រា ១៤ ថ្មី.—**

១-ចៅក្រមទាំងអស់ត្រូវព្យាយាមសម្រេចឱ្យបានភាពឯកច្ឆ័ន្ទក្នុងសេចក្ដីសម្រេចរបស់ខ្លួន ។ ប្រសិនបើភាពឯកច្ឆ័ន្ទនេះពុំអាចរកបានទេ ត្រូវអនុវត្តគោលការណ៍ដូចខាងក្រោម :

ក-ការសម្រេចសេចក្ដីដោយអង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូងតម្រូវឱ្យមានការបោះឆ្នោតគាំទ្រពីចៅក្រមបួនរូបយ៉ាងតិច ។

ខ-ការសម្រេចសេចក្ដីដោយអង្គជំនុំជម្រះវិសាមញ្ញរបស់តុលាការកំពូលតម្រូវឱ្យមានការបោះឆ្នោតគាំទ្រពីចៅក្រមប្រាំរូបយ៉ាងតិច ។

២-នៅពេលដែលពុំមានភាពឯកច្ឆ័ន្ទនោះទេ សេចក្តីសម្រេចនៃអង្គជំនុំជម្រះត្រូវកត់ត្រាទុកនូវយោបល់របស់មតិភាគច្រើននិងមតិភាគតិច ។

**មាត្រា ១៧ ថ្មី.-**

សហព្រះរាជអាជ្ញានៃសាលាដំបូងមានសិទ្ធិប្តឹងឧទ្ធរណ៍ពីសេចក្តីសម្រេចនៃអង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូង ។

**មាត្រា ១៨ ថ្មី.-**

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវជ្រើសតាំងព្រះរាជអាជ្ញា និងព្រះរាជអាជ្ញាបម្រុងខ្មែរមួយចំនួនតាមតម្រូវការពីក្របខ័ណ្ឌចៅក្រមវិជ្ជាជីវៈខ្មែរ ។

ព្រះរាជអាជ្ញាបម្រុងត្រូវជំនួសព្រះរាជអាជ្ញាពេញសិទ្ធិ នៅពេលដែលព្រះរាជអាជ្ញានោះអវត្តមាន ឬ មានធុរៈ ។

ព្រះរាជអាជ្ញាទាំងនេះអាចបន្តបំពេញការងារប្រចាំថ្ងៃនៅក្នុងសាលាជំនុំជម្រះក្តីដែលខ្លួនកំពុងបំពេញ ។

ព្រះរាជអាជ្ញាបរទេសមួយរូបដែលមានសមត្ថកិច្ចបង្ហាញខ្លួនក្នុងគ្រប់លំដាប់ថ្នាក់នៃអង្គជំនុំជម្រះវិសាមញ្ញ ត្រូវបានជ្រើសតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្រោយពីការជ្រើសរើសឱ្យឈរឈ្មោះដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

អគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវរៀបចំបញ្ជីបេក្ខជនយ៉ាងតិចពីររូបជាសហព្រះរាជអាជ្ញាបរទេសជូនរាជរដ្ឋាភិបាលកម្ពុជា ហើយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវជ្រើសតាំងព្រះរាជអាជ្ញាពេញសិទ្ធិមួយរូប និងព្រះរាជអាជ្ញាបម្រុងមួយរូបចេញពីបញ្ជីបេក្ខជននេះ ។

**មាត្រា ២០ ថ្មី.-**

សហព្រះរាជអាជ្ញាត្រូវធ្វើការចោទប្រកាន់ដោយអនុវត្តតាមនីតិវិធីដែលនៅជាធរមាន ។ ប្រសិនបើនីតិវិធីដែលមានស្រាប់ពុំបានចែងពីករណីពិសេសមួយ ឬ ប្រសិនបើ

មានភាពមិនច្បាស់លាស់ក្នុងការបកស្រាយ ឬ អនុវត្តនីតិវិធីនោះ ឬ ប្រសិនបើមានបញ្ហាទាក់ទងទៅនឹងភាពសមស្របនៃនីតិវិធីទាំងនេះជាមួយបទដ្ឋានអន្តរជាតិ សហព្រះរាជអាជ្ញាអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ ។

ក្នុងករណីដែលមានភាពខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា ត្រូវអនុវត្តគោលការណ៍ដូចខាងក្រោម :

ការចោទប្រកាន់ត្រូវបន្ត ដរាបណាសហព្រះរាជអាជ្ញា ឬ ក៏សហព្រះរាជអាជ្ញាម្នាក់ពុំបានស្នើក្នុងរយៈពេលសាមសិបថ្ងៃថា ភាពខ្វែងយោបល់គ្នាត្រូវបានដោះស្រាយ ដោយអនុលោមតាមបទប្បញ្ញត្តិដូចខាងក្រោម :

សហព្រះរាជអាជ្ញាត្រូវដាក់ជូននូវកំណត់ហេតុជាលាយលក្ខណ៍អក្សរអំពីអង្គហេតុ និងហេតុផលទាំងឡាយ ចំពោះគោលជំហរខុសគ្នារបស់គេ ដល់ប្រធានការិយាល័យរដ្ឋបាល ។

ភាពខ្វែងយោបល់គ្នាត្រូវតែដោះស្រាយភ្លាម ដោយអង្គបុរេជំនុំជម្រះដែលមានចៅក្រមប្រាំរូប ចៅក្រមខ្មែរបីរូប ត្រូវបានជ្រើសតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដោយមានចៅក្រមមួយរូបជាប្រធាន ហើយនិងចៅក្រមបរទេសពីររូប ត្រូវបានជ្រើសតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម បន្ទាប់ពីមានការជ្រើសរើសឱ្យឈរឈ្មោះដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

ការជ្រើសរើសចៅក្រមខាងលើនេះត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃមាត្រា ១០ ថ្មី នៃច្បាប់នេះ ។

បន្ទាប់ពីទទួលបានកំណត់ហេតុដូចដែលមានចែងនៅក្នុងកថាខ័ណ្ឌទី ៣ ប្រធានការិយាល័យរដ្ឋបាលត្រូវកោះប្រជុំអង្គបុរេជំនុំជម្រះជាបន្ទាន់ ហើយត្រូវជូនដំណឹងអំពីកំណត់ហេតុដល់សមាជិកអង្គបុរេជំនុំជម្រះ ។

សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះដែលពុំបើកផ្លូវឱ្យមានបណ្តឹងឧទ្ធរណ៍តម្រូវឱ្យមានសំឡេងវិជ្ជមានពីចៅក្រមបួនរូបយ៉ាងតិច ។ សេចក្តីសម្រេចនេះត្រូវជូនដំណឹងដល់ប្រធានការិយាល័យរដ្ឋបាលដែលត្រូវផ្សព្វផ្សាយសេចក្តីសម្រេចនេះ ហើយជូនដំណឹងដល់សហព្រះរាជអាជ្ញា ។ សហព្រះរាជអាជ្ញាត្រូវចាត់ការបន្តជាបន្ទាន់ដោយអនុវត្តតាមសេចក្តី

សម្រេចរបស់អង្គជំនុំជម្រះ ។ ប្រសិនបើពុំមានមតិភាគច្រើនដូចតម្រូវឱ្យមានចំពោះការធ្វើសេចក្តីសម្រេចទេ ការចោទប្រកាន់ត្រូវធ្វើបន្តទៅទៀត ។

ក្នុងពេលធ្វើការចោទប្រកាន់ សហព្រះរាជអាជ្ញាអាចស្វែងរកការជួយឧបត្ថម្ភពីរាជរដ្ឋាភិបាលកម្ពុជាប្រសិនបើការជួយឧបត្ថម្ភនេះពិតជាមានប្រយោជន៍ចំពោះការចោទប្រកាន់ ហើយការជួយឧបត្ថម្ភនេះត្រូវតែផ្តល់ជូន ។

**មាត្រា ២១ ថ្មី.–**

សហព្រះរាជអាជ្ញាទាំងអស់ដែលស្ថិតក្រោមច្បាប់នេះមានឋានៈ និង លក្ខខណ្ឌការងារស្មើៗគ្នា ទៅតាមលំដាប់ថ្នាក់នៃអង្គជំនុំជម្រះវិសាមញ្ញនីមួយៗ ។

ព្រះរាជអាជ្ញាម្នាក់ៗ ត្រូវបានជ្រើសតាំងសម្រាប់រយៈពេលនៃការជំនុំជម្រះ ។

ក្នុងករណីដែលព្រះរាជអាជ្ញាបរទេសអវត្តមានឬមានធុរៈ ត្រូវជំនួសដោយព្រះរាជអាជ្ញាបម្រុងបរទេស ។

**មាត្រា ២២ ថ្មី.–**

សហព្រះរាជអាជ្ញាម្នាក់ៗមានសិទ្ធិជ្រើសរើសព្រះរាជអាជ្ញារងម្នាក់ ឬ ច្រើនរូប ដើម្បីជួយខ្លួនក្នុងការធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់នៅចំពោះមុខអង្គជំនុំជម្រះ ។ ព្រះរាជអាជ្ញារងបរទេសត្រូវតែងតាំងដោយសហព្រះរាជអាជ្ញាបរទេសពីបញ្ជីផ្តល់ដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

សហព្រះរាជអាជ្ញាត្រូវមានបុគ្គលិកខ្មែរ និងបុគ្គលិកអន្តរជាតិជាជំនួយការទៅតាមតម្រូវការជាក់ស្តែង សម្រាប់បម្រើការងារនៅការិយាល័យរបស់ខ្លួន ។

ក្នុងការជ្រើសរើសបុគ្គលិកជាជំនួយការ ប្រធានការិយាល័យរដ្ឋបាលត្រូវធ្វើសម្ភាសន៍ក្នុងករណីចាំបាច់ និងត្រូវមានការយល់ព្រមពីសហព្រះរាជអាជ្ញាខ្មែរក្នុងការជួលបុគ្គលិកដែលត្រូវតែងតាំងដោយរាជរដ្ឋាភិបាលកម្ពុជា ។ អនុប្រធានការិយាល័យរដ្ឋបាលត្រូវទទួលខុសត្រូវចំពោះការជ្រើសរើសនិងការគ្រប់គ្រងបុគ្គលិកបរទេសទាំងអស់ ។ ចំនួនបុគ្គលិកជំនួយការត្រូវជ្រើសរើសតាមសមាមាត្រព្រះរាជអាជ្ញាខ្មែរនិងព្រះរាជអាជ្ញាបរទេស ។

បុគ្គលិកជាជំនួយការខ្មែរត្រូវជ្រើសរើសក្នុងចំណោមមន្ត្រីរាជការក្នុងក្របខ័ណ្ឌរដ្ឋ ឬ ជនជាតិខ្មែរដទៃទៀត ដែលមានសមត្ថភាពក្នុងករណីចាំបាច់ ។

**មាត្រា ២៣ ថ្មី.—**

រាល់ការស៊ើបអង្កេត គឺជាការទទួលខុសត្រូវរួមគ្នារបស់ចៅក្រមពីរនាក់ ម្នាក់ជាខ្មែរ និងម្នាក់ទៀតជាបរទេស ដែលហៅថា "សហចៅក្រមស៊ើបអង្កេត" ដោយអនុវត្តតាមនីតិវិធីដែលនៅជាធរមាន ។ ប្រសិនបើនីតិវិធីដែលមានស្រាប់ពុំបានចែងពីករណីពិសេសមួយ ឬ ប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយ ឬ អនុវត្តនីតិវិធីនោះ ឬ ប្រសិនបើមានបញ្ហាទាក់ទងទៅនឹងភាពសមស្របនៃនីតិវិធីទាំងនេះជាមួយបទដ្ឋានអន្តរជាតិ សហចៅក្រមស៊ើបអង្កេតអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធី ដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ ។

ក្នុងករណីដែលមានភាពមិនយល់ស្របគ្នារវាងសហចៅក្រម ត្រូវអនុវត្តគោលការណ៍ដូចខាងក្រោម :

ការស៊ើបអង្កេតត្រូវធ្វើបន្ត ដរាបណាសហចៅក្រមស៊ើបអង្កេតទាំងពីរឬមួយរូបក្នុងចំណោមពួកគេពុំបានប្ដឹងមិនសុខចិត្តក្នុងរយៈពេលសាមសិបថ្ងៃថា ភាពខ្វែងយោបល់គ្នាត្រូវដោះស្រាយដោយអនុវត្តតាមបទប្បញ្ញត្តិដូចខាងក្រោម :

សហចៅក្រមស៊ើបអង្កេតត្រូវជូនកំណត់ហេតុជាលាយល័ក្ខណ៍អក្សរ អំពីអង្គហេតុ និងហេតុផលទាំងឡាយ ចំពោះគោលជំហរខុសគ្នា ដល់ប្រធានការិយាល័យរដ្ឋបាល ។

ភាពខ្វែងយោបល់គ្នាត្រូវដោះស្រាយភ្លាមដោយអង្គបុរេជំនុំជម្រះ ដូចមានចែងក្នុងមាត្រា ២០ ថ្មី នៃច្បាប់នេះ ។

បន្ទាប់ពីទទួលបាននូវកំណត់ហេតុដូចមានចែងក្នុងកថាខ័ណ្ឌទី ៣ រួចមក ប្រធានការិយាល័យរដ្ឋបាលត្រូវកោះប្រជុំអង្គបុរេជំនុំជម្រះជាបន្ទាន់ ហើយជូនដំណឹងអំពីកំណត់ហេតុដល់សមាជិកអង្គបុរេជំនុំជម្រះ ។

សេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះដែលពុំបើកផ្លូវឱ្យមានបណ្ដឹងឧទ្ធរណ៍ តម្រូវឱ្យមានសំឡេងវិជ្ជមានពីចៅក្រមបួនរូបយ៉ាងតិច ។ សេចក្ដីសម្រេចនេះត្រូវជូនដំណឹង

ដល់ប្រធានការិយាល័យរដ្ឋបាលដែលត្រូវផ្សព្វផ្សាយសេចក្តីសម្រេចនេះ ហើយជូនដំណឹងដល់សហចៅក្រមស៊ើបអង្កេត ។ សហចៅក្រមស៊ើបអង្កេតត្រូវចាត់ការបន្តជាបន្ទាន់ ដោយអនុវត្តតាមសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះនេះ ។ ប្រសិនបើពុំមានមតិភាគច្រើនដូចដែលតម្រូវឱ្យមានចំពោះសេចក្តីសម្រេច ការស៊ើបអង្កេតត្រូវធ្វើបន្តទៀត ។

សហចៅក្រមស៊ើបអង្កេត អាចផ្អែកទៅលើមូលដ្ឋាននៃព័ត៌មានដែលទទួលបានពីស្ថាប័ននានារួមមានរដ្ឋាភិបាល ស្ថាប័ននានារបស់អង្គការសហប្រជាជាតិ ឬ អង្គការក្រៅរដ្ឋាភិបាលជាដើម ។

សហចៅក្រមស៊ើបអង្កេតមានអំណាចក្នុងការសួរចម្លើយជនសង្ស័យ ជនរងគ្រោះ និងស្តាប់ចម្លើយសាក្សី និងប្រមូលភស្តុតាងដោយអនុវត្តតាមនីតិវិធីជាធរមាន ។ ក្នុងករណីដែលសហចៅក្រមស៊ើបអង្កេតយល់ថាជាការចាំបាច់ខានមិនបាន សហចៅក្រមស៊ើបអង្កេត អាចចេញដីកាសុំឱ្យសហព្រះរាជអាជ្ញាធ្វើការសាកសួរសាក្សីបន្ថែមបាន ។

ក្នុងការអនុវត្តភារកិច្ចនេះ សហចៅក្រមស៊ើបអង្កេតអាចស្វែងរកការជួយឧបត្ថម្ភពីរាជរដ្ឋាភិបាលកម្ពុជាបាន ប្រសិនបើយល់ឃើញថាសមស្របនិងមានប្រយោជន៍ដល់ការស៊ើបអង្កេត ហើយការជួយឧបត្ថម្ភនេះត្រូវតែបានផ្តល់ជូន ។

**មាត្រា ២៤ ថ្មី.–**

ក្នុងដំណាក់កាលស៊ើបអង្កេត ជនសង្ស័យមានសិទ្ធិទទួលបានការការពារពីមេធាវីដែលជ្រើសរើសដោយខ្លួនឯងដោយខានមិនបាន និងមានជំនួយផ្នែកច្បាប់ដល់ពួកគេដោយឥតគិតថ្លៃ ប្រសិនបើខ្លួនគ្មានលទ្ធភាពគ្រប់គ្រាន់ដើម្បីពឹងមេធាវី ព្រមទាំងមានសិទ្ធិទទួលបាននូវការបកប្រែចាំបាច់ជាភាសាដែលជនសង្ស័យនិយាយនិងយល់បាន ។

**មាត្រា ២៧ ថ្មី.–**

ចៅក្រមស៊ើបអង្កេតទាំងអស់ដែលស្ថិតក្រោមច្បាប់នេះមានឋានៈនិងលក្ខខណ្ឌការងារស្មើៗគ្នា ។

ចៅក្រមស៊ើបអង្កេតមួយរូបៗ ត្រូវបានជ្រើសតាំងសម្រាប់រយៈពេលនៃការស៊ើបអង្កេត ។

ក្នុងករណីដែលសហចៅក្រមស៊ើបអង្កេតបរទេសណាមួយអវត្តមាន ឬ មានធុរៈ ត្រូវជំនួសដោយចៅក្រមស៊ើបអង្កេតបម្រុងបរទេស ។

**មាត្រា ២៩ ថ្មី.–**

ជនសង្ស័យណាមួយដែលមានផែនការញុះញង់ បញ្ជា ប្រព្រឹត្ត ឬ ជួយនិងជំរុញក្នុងការរៀបចំផែនការ ឬ ការប្រព្រឹត្តឧក្រិដ្ឋកម្មក្នុងមាត្រា ៣ថ្មី, ៤, ៥, ៦, ៧ និងមាត្រា ៨ នៃច្បាប់នេះ ត្រូវទទួលខុសត្រូវជាបុគ្គលចំពោះឧក្រិដ្ឋកម្មនេះ ។

តួនាទី ឬ ឋានៈរបស់ជនសង្ស័យមិនអាចជួយជននេះឱ្យរួចផុតពីការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋ ឬ ជួយបន្ថយទណ្ឌកម្មដល់ជននេះបានឡើយ ។

ប្រការដែលថាសកម្មភាពណាមួយក្នុងចំណោមសកម្មភាពដែលមានចែងក្នុងមាត្រា ៣ថ្មី, ៤, ៥, ៦, ៧ និង មាត្រា ៨ នៃច្បាប់នេះត្រូវបានប្រព្រឹត្តដោយអ្នកនៅក្រោមបង្គាប់នោះ មិនអាចជួយឱ្យថ្នាក់លើរួចផុតពីការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនោះបានទេ ប្រសិនបើថ្នាក់លើមានបញ្ជា និង មានការគ្រប់គ្រងដ៏មានប្រសិទ្ធិភាព ឬ មានអំណាច និង ការត្រួតពិនិត្យទៅលើអ្នកនៅក្រោមបង្គាប់ ហើយថ្នាក់លើបានដឹង និងមានហេតុផលដឹងថាអ្នកនៅក្រោមបង្គាប់ ប្រព្រឹត្ត ឬ បានប្រព្រឹត្តនូវសកម្មភាពបែបនេះ ហើយខ្លួនមិនបានចាត់វិធានការចាំបាច់និងសមស្រប ដើម្បីបង្ការអំពើបែបនេះ ឬ ដាក់ទណ្ឌកម្មចំពោះការប្រព្រឹត្តបទឧក្រិដ្ឋនេះ ។

ប្រការដែលថាជនសង្ស័យបានប្រព្រឹត្តអំពើឧក្រិដ្ឋទៅតាមបញ្ជារបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ឬ របស់ថ្នាក់លើណាមួយ មិនអាចជួយជនសង្ស័យនេះឱ្យរួចផុតពីការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋនេះបានឡើយ ។

**មាត្រា ៣១ ថ្មី.–**

ប្រធានការិយាល័យរដ្ឋបាលត្រូវតែងតាំងដោយរាជរដ្ឋាភិបាលកម្ពុជា សម្រាប់រយៈពេល ២ ឆ្នាំ ហើយអាចត្រូវបានតែងតាំងបន្តទៀតបាន ។ ប្រធានការិយាល័យរដ្ឋបាល

មានភារកិច្ចគ្រប់គ្រងទូទៅលើការងាររបស់ការិយាល័យរដ្ឋបាល លើកលែងតែការងារដែលស្ថិតនៅក្រោមបទប្បញ្ញត្តិ និងនីតិវិធីរបស់អង្គការសហប្រជាជាតិ ។

ប្រធានការិយាល័យរដ្ឋបាលត្រូវបានជ្រើសរើសក្នុងចំណោមអ្នកដែលមានបទពិសោធន៍ខ្ពស់ក្នុងការងាររដ្ឋបាល តុលាការ មានភាពស្ទាត់ជំនាញលើភាសាណាមួយក្នុងចំណោមភាសាបរទេសដែលប្រើការក្នុងអង្គជំនុំជម្រះវិសាមញ្ញ ជាមនុស្សមានចរិតលក្ខណៈ និងស្មារតីខ្ពស់ និងសុចរិត ។

អនុប្រធានបរទេសនៃការិយាល័យរដ្ឋបាល ត្រូវជ្រើសតាំងដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ និង តែងតាំងដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងត្រូវទទួលខុសត្រូវចំពោះការជ្រើសរើសនិងការគ្រប់គ្រងបុគ្គលិកអន្តរជាតិទាំងអស់ ដូចៗ ដែលបានតម្រូវឱ្យមានដោយសមាសភាគបរទេសនៃអង្គជំនុំជម្រះវិសាមញ្ញ សហចៅក្រមស៊ើបអង្កេត ការិយាល័យនៃសហព្រះរាជអាជ្ញានិងការិយាល័យរដ្ឋបាល ។ អនុប្រធានការិយាល័យរដ្ឋបាលត្រូវគ្រប់គ្រងប្រាក់ ធនធានដែលផ្តល់ជូនតាមរយៈមូលនិធិស្ម័គ្រចិត្តនៃអង្គការសហប្រជាជាតិ ។

ការិយាល័យរដ្ឋបាលត្រូវមានបុគ្គលិកខ្មែរនិងបុគ្គលិកអន្តរជាតិជាជំនួយការតាមតម្រូវការជាក់ស្តែង ។

បុគ្គលិកខ្មែរទាំងអស់នៃការិយាល័យរដ្ឋបាលត្រូវតែងតាំងដោយរាជរដ្ឋាភិបាលកម្ពុជា តាមសំណើរបស់ប្រធានការិយាល័យ ។ បុគ្គលិកបរទេសត្រូវតែងតាំងដោយអនុប្រធានការិយាល័យរដ្ឋបាល ។

បុគ្គលិកខ្មែរត្រូវជ្រើសរើសក្នុងចំណោមមន្ត្រីរាជការក្នុងក្របខ័ណ្ឌរដ្ឋ ឬ ជនជាតិខ្មែរដទៃទៀត ដែលមានសមត្ថភាពក្នុងករណីចាំបាច់ ។

**មាត្រា ៣៣ ថ្មី.—**

អង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូងត្រូវប្រព្រឹត្តទៅឱ្យបានត្រឹមត្រូវនិងឆាប់រហ័សទៅតាមនីតិវិធីជាធរមាន ដោយមានការគោរពយ៉ាងពេញលេញនូវសិទ្ធិរបស់ជនត្រូវចោទ និងមានការការពារឱ្យបានត្រឹមត្រូវចំពោះជនរងគ្រោះនិងសាក្សី ។ ប្រសិនបើនីតិវិធីដែលមានស្រាប់ពុំបានចែងពីករណីពិសេសមួយ ឬ ប្រសិនបើមានភាពមិនច្បាស់

លាស់ក្នុងការបកស្រាយ ឬ អនុវត្តនីតិវិធីនោះ ឬ ប្រសិនបើមានបញ្ហាទាក់ទងទៅនឹងភាពសមស្របនៃនីតិវិធីទាំងនេះជាមួយបទដ្ឋានអន្តរជាតិ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ ។ អង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូងត្រូវអនុវត្តយុត្តាធិការរបស់ខ្លួនសមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវនិងដំណើរការសមស្របនៃច្បាប់ដូចដែលបានចែងក្នុងមាត្រា ១៤ និង ១៥ នៃអនុសញ្ញាអន្តរជាតិឆ្នាំ ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ ។ ជនសង្ស័យដែលត្រូវបានចោទប្រកាន់ហើយត្រូវបានចាប់ខ្លួន ត្រូវបញ្ជូនខ្លួនមកសាលាដំបូងតាមនីតិវិធីជាធរ-មាន ។ រាជរដ្ឋាភិបាលត្រូវទទួលខុសត្រូវក្នុងការធានាសន្តិសុខចំពោះការចូលខ្លួន និងក្នុងការចាត់ការឱ្យចាប់ខ្លួនជនសង្ស័យ ដែលត្រូវបានចោទប្រកាន់តាមច្បាប់នេះ ។ នគរបាលយុត្តិធម៌ត្រូវបានជួយឧបត្ថម្ភដោយអង្គភាពអនុវត្តច្បាប់ផ្សេងៗទៀតរបស់រាជរដ្ឋាភិបាលដែលរួមមានកងកម្លាំងប្រដាប់អាវុធ ដើម្បីធានានាឱ្យជនដែលត្រូវបានចោទប្រកាន់ត្រូវបាននាំខ្លួនមកក្នុងមន្ទីរឃុំឃាំងភ្លាមៗ ។ លក្ខខណ្ឌនៃការចាប់ខ្លួននិងឃុំខ្លួនត្រូវអនុវត្តតាមច្បាប់ជាធរមាន ។

តុលាការត្រូវផ្តល់ការការពារដល់ជនរងគ្រោះនិងសាក្សី ។ វិធានការការពារទាំងនេះមិនត្រូវកម្រិតត្រឹមតែកិច្ចដំណើរការជំនុំជម្រះជាសម្ងាត់ និងការការពារនូវអត្តសញ្ញាណរបស់ជនរងគ្រោះឡើយ ។

**មាត្រា ៣៤ ថ្មី.--**

អង្គជំនុំជម្រះវិសាមញ្ញត្រូវធ្វើជាសាធារណៈនិងបើកចំហសំរាប់តំណាងរបស់រដ្ឋបរទេស តំណាងរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ តំណាងបណ្តាញព័ត៌មាន និងតំណាងអង្គការក្រៅរដ្ឋាភិបាលជាតិនិងអន្តរជាតិ លើកលែងតែក្នុងកាលៈ-ទេសៈពិសេស អង្គជំនុំជម្រះវិសាមញ្ញសម្រេចថា ត្រូវជំនុំជម្រះជាសម្ងាត់ដោយមានមូល-ហេតុត្រឹមត្រូវ ដោយយោងតាមនីតិវិធីជាធរមាន ដែលការផ្សព្វផ្សាយជាសាធារណៈធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍យុត្តិធម៌ ។

**មាត្រា ៣៥ ថ្មី.-**

ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ ។

នៅក្នុងការចោទប្រកាន់មកលើខ្លួន ជនជាប់ចោទមានសិទ្ធិទទួលបាននូវការធានាជាអប្បបរមានិងស្មើៗគ្នាសមស្របតាមមាត្រា ១៤ នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយឆ្នាំ ១៩៦៦ :

ក/ ទទួលព័ត៌មានភ្លាមៗ និងលម្អិតជាភាសាដែលខ្លួនយល់បានអំពីប្រភេទ និង មូលហេតុនៃការចោទប្រកាន់ចំពោះខ្លួន

ខ/ មានពេលវេលា និងលក្ខណៈគ្រប់គ្រាន់ដើម្បីរៀបចំការពារខ្លួន និងទាក់ទងជាមួយមេធាវីរបស់ខ្លួនដែលជ្រើសរើសដោយខ្លួនឯង

គ/ ត្រូវបានទទួលការជំនុំជម្រះដោយគ្មានការអូសបន្លាយ

ឃ/ ត្រូវបានជំនុំជម្រះដោយមានវត្តមានរបស់ជនសង្ស័យនិងការពារខ្លួនដោយខ្លួនឯង ឬ តាមរយៈមេធាវីដែលជ្រើសរើសដោយខ្លួនឯង ត្រូវបានប្រាប់អោយដឹងអំពីសិទ្ធិ និង ទទួលបាននូវជំនួយផ្នែកច្បាប់ដោយឥតគិតថ្លៃ ប្រសិនបើជនជាប់ចោទគ្មានលទ្ធភាពជួលដោយខ្លួនឯង

ង/ ពិនិត្យភស្តុតាងដាក់បន្ទុក និងទទួលបាននូវការចូលរួម និងការពិនិត្យភស្តុតាងដោះបន្ទុកក្នុងលក្ខខណ្ឌដូចគ្នា និងភស្តុតាងដាក់បន្ទុកដែរ

ច/ មានការជួយឧបត្ថម្ភដោយសេរីពីអ្នកបកប្រែភាសា ប្រសិនបើជនជាប់ចោទមិនយល់ ឬ មិនអាចនិយាយបាននូវភាសាដែលប្រើនៅក្នុងតុលាការ

ឆ/ មិនត្រូវបានគេបង្ខំឱ្យឆ្លើយប្រឆាំងនឹងខ្លួនឯង ឬ បង្ខំឱ្យឆ្លើយសារភាពថាមានកំហុស ។

**មាត្រា ៣៦ ថ្មី.-**

អង្គជំនុំជម្រះវិសាមញ្ញនៃតុលាការកំពូលជំនុំជម្រះលើបណ្តឹងសាទុក្ខរបស់ជនជាប់ចោទ របស់ជនរងគ្រោះនិងរបស់សហព្រះរាជអាជ្ញា ពីសាលក្រមរបស់អង្គជំនុំជម្រះ

វិសាមញ្ញនៃសាលាដំបូង ក្នុងករណីនេះតុលាការកំពូលពិនិត្យសម្រេចជាចុងក្រោយទាំងអង្គហេតុ ទាំងអង្គច្បាប់ ដោយមិនបញ្ជូលសំណុំរឿងមកអង្គជំនុំជម្រះវិសាមញ្ញនៃសាលាដំបូងវិញទេ ។

**មាត្រា ៣៧ ថ្មី.-**

ប្រការដែលបានចែងនៅក្នុងមាត្រា ៣៣ថ្មី ៣៤ថ្មី និង ៣៥ថ្មី ត្រូវអនុវត្តដូចគ្នាចំពោះការជំនុំជម្រះក្ដីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញនៃតុលាការកំពូល ។

**មាត្រា ៣៩ ថ្មី.-**

ជនទាំងឡាយដែលប្រព្រឹត្តបទឧក្រិដ្ឋណាមួយដូចមានចែងក្នុងមាត្រា ៣ថ្មី, ៤, ៥, ៦, ៧ និង មាត្រា ៨ នៃច្បាប់នេះ ត្រូវផ្ដន្ទាទោសឧក្រិដ្ឋដាក់ពន្ធនាគារពី ៥ ឆ្នាំ រហូតដល់មួយជីវិត ។

ក្រៅពីទោសដាក់ពន្ធនាគារ អង្គជំនុំជម្រះវិសាមញ្ញនៃសាលាដំបូង អាចសម្រេចរឹបអូសទ្រព្យសម្បត្តិជាចលនវត្ថុ និងអចលនវត្ថុ និងលុយកាក់ដែលទទួលបានដោយខុសច្បាប់ ឬ ក៏បានដោយការប្រព្រឹត្តអំពើឧក្រិដ្ឋកម្ម ។ ទ្រព្យសម្បត្តិដែលរឹបអូសបាននេះ ត្រូវប្រគល់ជូនរដ្ឋ ។

**មាត្រា ៤០ ថ្មី.-**

រាជរដ្ឋាភិបាលកម្ពុជាមិនអាចស្នើសុំឱ្យមានការលើកលែងទោស ឬ ការអនុគ្រោះទោសដល់ជនទាំងឡាយណាដែលអាចត្រូវបានស៊ើបអង្កេត ឬ ត្រូវបានផ្ដន្ទាទោសអំពីឧក្រិដ្ឋកម្មដែលមានចែងក្នុងមាត្រា ៣ថ្មី, ៤, ៥, ៦, ៧ និង មាត្រា ៨ នៃច្បាប់នេះបានឡើយ ។ វិសាលភាពនៃការលើកលែងទោស ឬ អនុគ្រោះទោសដែលអាចត្រូវបានផ្ដល់អោយមុនការអនុម័តច្បាប់នេះ គឺត្រូវសំរេចដោយអង្គជំនុំជម្រះវិសាមញ្ញ ។

**មាត្រា ៤២ ថ្មី.-**

១-ចៅក្រមខ្មែរ សហចៅក្រមស៊ើបអង្កេតខ្មែរ សហព្រះរាជអាជ្ញាខ្មែរ និង បុគ្គលិកខ្មែរត្រូវបានផ្ដល់អភ័យឯកសិទ្ធិឱ្យរួចផុតពីដំណើរក្ដីតាមផ្លូវច្បាប់ ចំពោះពាក្យពេចន៍ដែល

បាននិយាយ ឬ សរសេរ និងសកម្មភាពទាំងអស់ដែលបានបំពេញក្នុងតំណែងផ្លូវការរបស់គេ ។ អភ័យឯកសិទ្ធិបែបនេះនៅតែមានជាបន្ត ក្រោយពីពួកគេបញ្ចប់ការងារជាមួយអង្គជំនុំជម្រះវិសាមញ្ញ អង្គបុរេជំនុំជម្រះ និង ការិយាល័យរដ្ឋបាល ។

២-បុគ្គលិកអន្តរជាតិត្រូវបានផ្តល់បន្ថែមនូវ :

ក-អភ័យឯកសិទ្ធិឱ្យរួចផុតពីដំណើរក្តីតាមផ្លូវច្បាប់ចំពោះពាក្យពេចន៍ ដែលបាននិយាយ ឬ សរសេរ និងសកម្មភាពទាំងអស់ដែលបានបំពេញក្នុងតំណែងផ្លូវការរបស់ពួកគេ ។ អភ័យឯកសិទ្ធិបែបនេះនៅតែមានជាបន្ត ក្រោយពីពួកគេបញ្ចប់ការងារជាមួយសហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា អង្គជំនុំជម្រះវិសាមញ្ញ អង្គបុរេជំនុំជម្រះ និង ការិយាល័យរដ្ឋបាល ។

ខ-អភ័យឯកសិទ្ធិឱ្យរួចផុតពីការបង់ពន្ធលើប្រាក់បៀវត្សរ៍ វិភាជន៍ និង ហិរលាភដែលបើកជូនពួកគេដោយអង្គការសហប្រជាជាតិ ។

គ-អភ័យឯកសិទ្ធិឱ្យរួចផុតពីការដាក់កំហិតព្រំដែនអន្តោប្រវេសន៍ ។

ឃ-សិទ្ធិនាំចូលដោយរួចពន្ធអាករ គ្រឿងសង្ហារិមនិងសម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួនរបស់ពួកគេលើកលែងតែការចំណាយសម្រាប់សេវាកម្ម នៅពេលដែលមកទទួលភារកិច្ចផ្លូវការជាលើកដំបូងនៅប្រទេសកម្ពុជា ។

៣-មេធាវីរបស់ជនសង្ស័យ ឬ ជនជាប់ចោទដែលត្រូវបានទទួលស្គាល់ថាជាមេធាវីដោយអង្គជំនុំជម្រះមិនត្រូវស្ថិតនៅក្រោមអំណាចរដ្ឋាភិបាល នូវវិធានការណាមួយដែលអាចប៉ះពាល់ដល់ការបំពេញមុខងារដោយសេរី និង ឯករាជ្យរបស់ខ្លួន នៅក្រោមច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ។

ជាពិសេស មេធាវីត្រូវបានផ្តល់នូវ :

ក-អភ័យឯកសិទ្ធិឱ្យរួចផុតពីការចាប់ ឬ ឃុំខ្លួន និងការរឹបអូសរបស់របរផ្ទាល់ខ្លួន ក្នុងក្របខ័ណ្ឌនៃការបំពេញភារកិច្ចរបស់ខ្លួនក្នុងរឿងក្តីនេះ

ខ-ភាពមិនអាចរំលោភបំពានបាននូវឯកសារទាំងអស់ដែលទាក់ទងដល់ការបំពេញមុខងាររបស់ខ្លួនជាមេធាវីរបស់ជនសង្ស័យ ឬ ជនជាប់ចោទ

គ-អភ័យឯកសិទ្ធិឱ្យរួចផុតពីយុត្តាធិការរដ្ឋប្បវេណីនិងព្រហ្មទណ្ឌចំពោះពាក្យពេចន៍ដែលបាននិយាយឬសរសេរ និង សកម្មភាពដែលបានបំពេញក្នុងតំណែងផ្លូវការរបស់គេក្នុងនាមជាមេធាវី ។ អភ័យឯកសិទ្ធិបែបនេះនៅបន្តផ្តល់ចំពោះពួកគេក្រោយពួកគេបញ្ចប់មុខងារជាមេធាវីរបស់ជនសង្ស័យ ឬ ជនជាប់ចោទ ។

៤-បណ្ណសារដ្ឋានរបស់សហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា អង្គជំនុំជម្រះវិសាមញ្ញ អង្គបុរេជំនុំជម្រះ និងការិយាល័យរដ្ឋបាលនិងជាទូទៅឯកសារ និង សម្ភារៈទាំងអស់ដែលអាចរកបាន ហើយដែលជាកម្មសិទ្ធិរបស់អ្នកទាំងនោះ ឬ ប្រើប្រាស់ដោយអ្នកទាំងនោះ ទោះជាស្ថិតនៅកន្លែងណានៃព្រះរាជាណាចក្រកម្ពុជាក៏ដោយនិងគ្រប់គ្រងដោយជនណាក៏ដោយ គឺមិនអាចត្រូវបានរំលោភបំពានបាន ក្នុងរយៈពេលនៃកិច្ចដំណើរការជំនុំជម្រះនេះឡើយ ។

**មាត្រា ៤៣ ថ្មី.-**

អង្គជំនុំជម្រះវិសាមញ្ញដែលធ្វើឡើងនៅថ្នាក់សាលាដំបូងនិងតុលាការកំពូលមានទីតាំងនៅក្នុងទីក្រុងភ្នំពេញ ។

**មាត្រា ៤៤ ថ្មី.-**

ការចំណាយនិងប្រាក់បៀវត្សរបស់អង្គជំនុំជម្រះវិសាមញ្ញមាន :

១-ការចំណាយនិងប្រាក់បៀវត្សចំពោះមន្ត្រីរដ្ឋបាលនិងបុគ្គលិកខ្មែរចំពោះចៅក្រមជម្រះក្តី និងចៅក្រមជម្រះក្តីបម្រុង ចៅក្រមស៊ើបអង្កេត និងចៅក្រមស៊ើបអង្កេតបម្រុង ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញាបម្រុងខ្មែរទាំងអស់ជាបន្ទុករបស់ថវិកាជាតិខ្មែរ ។

២-ការចំណាយចំពោះមន្ត្រីរដ្ឋបាលនិងបុគ្គលិកបរទេស ចៅក្រមជម្រះក្តី សហ-ព្រះរាជអាជ្ញានិងសហចៅក្រមស៊ើបអង្កេតបរទេសដែលបញ្ជូនមកដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ជាបន្ទុករបស់អង្គការសហប្រជាជាតិ ។

៣-មេធាវីការពារក្តី អាចទទួលប្រាក់កម្រៃពីកិច្ចការពារក្តីរបស់ខ្លួន ។

៤-ការចំណាយសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក៏អាចទទួលបន្ថែមនូវមូលនិធិស្ម័គ្រចិត្តដទៃទៀត ដូចជារដ្ឋាភិបាលបរទេស ស្ថាប័នអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាលនានា ហើយនិងបុគ្គលដែលមានបំណងចង់ជួយដល់កិច្ចដំណើរការនេះ ។

**មាត្រា ៤៥ ថ្មី.–**

ភាសាដែលប្រើប្រាស់ជាផ្លូវការក្នុងការងាររបស់អង្គជំនុំជម្រះវិសាមញ្ញគឺភាសាខ្មែរ ភាសាអង់គ្លេស និងភាសាបារាំង ។

**មាត្រា ៤៦ ថ្មី.–**

ដើម្បីធានាការអនុវត្តច្បាប់នេះបានទាន់ពេលវេលានិងមិនរអាក់រអួលក្នុងករណីដែលចៅក្រមជម្រះក្តី ឬ ចៅក្រមស៊ើបអង្កេត ឬ ព្រះរាជអាជ្ញាបរទេសណាមួយមិនបានចូលរួម ឬ បដិសេធមិនចូលរួមក្នុងអង្គជំនុំជម្រះវិសាមញ្ញ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជ្រើសតាំងចៅក្រមជម្រះក្តី ឬ ចៅក្រមស៊ើបអង្កេត ឬ ព្រះរាជអាជ្ញាផ្សេងទៀតឱ្យបំពេញកន្លែងទំនេរ ក្នុងចំណោមបញ្ជីបេក្ខជនបរទេសដែលមានចែងក្នុងមាត្រា ១១ ថ្មី មាត្រា ១៨ ថ្មី និង មាត្រា ២៦ នៃច្បាប់នេះ ។ ក្នុងករណីដែលឈ្មោះក្នុងបញ្ជីត្រូវបានប្រើអស់ ហើយលោកអគ្គលេខាធិការអង្គការសហប្រជាជាតិពុំបានផ្តល់បញ្ជីឈ្មោះបេក្ខជនថ្មីបន្ថែម ឬ ក្នុងករណីដែលអង្គការសហប្រជាជាតិដកការគាំទ្រពីអង្គជំនុំជម្រះវិសាមញ្ញកន្លែងទំនេរទាំងនោះ ត្រូវបំពេញបន្ថែមដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ពីបណ្តាបេក្ខជនដែលបានស្នើឡើងដោយរដ្ឋាភិបាលនៃបណ្តារដ្ឋជាសមាជិកនៃអង្គការសហប្រជាជាតិ ឬ ពីក្នុងចំណោមឥស្សរជនច្បាប់បរទេសដទៃទៀត ។

បន្ទាប់ពីអនុវត្តនីតិវិធីនេះហើយ បើនៅតែគ្មានចៅក្រមជម្រះក្តី ឬ ចៅក្រមស៊ើបអង្កេត ឬ ព្រះរាជអាជ្ញាបរទេសចូលរួមក្នុងការងាររបស់អង្គជំនុំជម្រះវិសាមញ្ញ ហើយគ្មានបេក្ខជនបរទេសណាត្រូវបានជ្រើសរើសឱ្យបំពេញតំណែងទំនេរនេះទេ នៅពេលនោះ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមអាចជ្រើសតាំងចៅក្រមជម្រះក្តី ឬ ចៅក្រមស៊ើបអង្កេត ឬ ព្រះរាជអាជ្ញាខ្មែរជំនួស ។

មាត្រា ៤៧ ស្ទួន.-

ក្រោយពេលផ្ដល់សច្ចាប័នសមស្របតាមបទប្បញ្ញត្តិនៃច្បាប់ព្រះរាជាណាចក្រកម្ពុជា ទាក់ទងទៅនឹងសមត្ថកិច្ចនៃការចុះសន្ធិសញ្ញា កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្ដីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ធ្វើនៅភ្នំពេញថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០០៣ ត្រូវអនុវត្តជាច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ពីរ.-

ច្បាប់នេះត្រូវប្រកាសជាការប្រញាប់ ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ តុលា ឆ្នាំ ២០០៤

ក្នុងព្រះបរមនាម

ប្រមុខរដ្ឋស្ដីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

៣រល.០៤១០.៣៣០

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្ដលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខៈ ... ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល